Clever Care HEALTH PLAN

# មគ្គុទ្ទេសក៍ឆ្លាតវៃចំពោះ
# អត្ថប្រយោជន៍បន្ថែម

**ស្វែងយល់ពីអត្ថប្រយោជន៍សុខភាពបន្ថែម ដែលរួមបញ្ចូលនៅក្នុងគម្រោង Clever Care HMO**



H7607_22_CM0652_M Accepted 09292021



# យើងខ្ញុំនិយាយភាសារបស់អ្នក

យើងខ្ញុំដឹងថាផ្នែកមួយនៃការមានសុខភាពល្អគឺមានភាពងាយស្រួល មិនមានការលំបាកក្នុងការទទួលបានការថែទាំដែលអ្នកត្រូវការ។ Clever Care ផ្តល់ជូនអតិថិជននូវសេវាកម្ម និងសម្ភារអត្ថប្រយោជន៍ជាភាសាដែលអ្នកងាយស្រួលនិយាយបំផុត។

ដើម្បីស្វែងយល់បន្ថែមអំពីគម្រោង **Clever Care Medicare Advantage** សូមចូលទៅកាន់គេហទំព័រ **clevercarehealthplan.com** ឬទូរសព្ទមកយើងខ្ញុំតាមរយៈលេខ **(833) 365-1888** (TTY: 711) ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8 យប់ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ពីថ្ងៃទី 1 ខែតុលា រហូតដល់ថ្ងៃទី 31 ខែមិនា និងពីម៉ោង 8 ព្រឹក ដល់ម៉ោង 8 យប់ នៅថ្ងៃធ្វើការ ចាប់ពីថ្ងៃទី 1 ខែមេសា រហូតដល់ថ្ងៃទី 30 ខែកញ្ញា។

# ទទួលបានការធានារ៉ាប់រងសុខភាពទាំងស្រុង ជាមួយ Clever Care

ដោយសារតែសុខុមាលភាពពេញលេញរបស់អ្នកមិនត្រូវបានកំណត់ចំពោះតែការថែទាំសុខភាពជាមូលដ្ឋាន វាគឺជាការសំខាន់ក្នុងការមានធានារ៉ាប់រងសុខភាពដែលរួមបញ្ចូលទាំងសេវាកម្មលើសពីអ្វីដែលរ៉ាប់រងដោយOriginalMedicare។

គម្រោង Clever Care Medicare Advantage ត្រូវបានរចនាឡើងដើម្បីផ្តល់ជូនសមាជិកមិនត្រឹមតែការធានារ៉ាប់រងសុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរ៉ាប់រងលើឱសថមានវេជ្ជបញ្ជា បូករួមទាំងសេវាសុខភាពមាត់ធ្មេញសុខភាពភ្នែកសុខភាពត្រចៀក កាយសម្បទា និងសេវាកម្មសុខុមាលភាពបែបលោកខាងកើត។



# អត្ថប្រយោជន៍បន្ថែមរបស់ Clever Care

គម្រោង Clever Care Medicare Advantage ទាំងអស់រួមបញ្ចូលទាំងអត្ថប្រយោជន៍ដែលមិនត្រូវបានរ៉ាប់រងដោយ Original Medicare ។ អត្ថប្រយោជន៍ទាំងនេះសំដៅចំពោះអត្ថប្រយោជន៍បន្ថែម។ អត្ថប្រយោជន៍បន្ថែមដែលបានរៀបរាប់ខាងក្រោមធ្វើការរួមគ្នាដើម្បីធានាថាអ្នកគឺជាអ្នកដែលមានសុខភាពល្អបំផុត។



## ឱសថនិងសេវាកម្មបែបលោកខាងកើត

ឱសថបែបលោកខាងកើតគឺជាចំណុចស្នូលនៃទស្សនវិជ្ជារបស់យើង។ ជាមួយនឹងគម្រោងរបស់យើងខ្ញុំ អ្នកអាចទទួលបាននូវការព្យាបាលដោយប្រើម្ជុលវិទ្យាសាស្ត្រ និងវិធីព្យាបាលបែបលោកខាងកើតផ្សេងទៀតដូចជា Gua Sha, Tui Na, ការជប់ខ្យល់ និងការព្យាបាលជាច្រើនទៀត – ដោយមិនចាំបាច់មានការបញ្ជូនបន្ត។ ***ត្រូវប្រាកដថាស្វែងរកសេវាកម្មពីអ្នកជំនាញផ្នែកព្យាបាលដោយប្រើម្ជុលវិទ្យាសាស្ត្រដែលមានអាជ្ញាប័ណ្ណនៅក្នុងបណ្តាញរបស់ Clever Care ។***



## សុខភាពមាត់ធ្មេញ

អ្នកសមនឹងទទួលបានស្នាមញញឹមដ៏ស្រស់ស្រាយ និងប្រកបដោយផាសុកភាព។ Clever Care ផ្តល់ជូនអ្នកនូវចំនួនប្រាក់ឧបត្ថម្ភដើម្បីជួយរ៉ាប់រងលើការសម្អាត ការពិនិត្យ ការប៉ះការស្រោប និងសេវាកម្មធ្មេញជាច្រើនទៀតប្រចាំឆ្នាំ។




## សុខភាពភ្នែក

ការមើលឃើញភាពស្រស់ស្អាតនៃពិភពលោកនៅជុំវិញខ្លួនអ្នក អាចនាំមកជូនអ្នកនូវសេចក្តីរីករាយ។ Clever Care ផ្តល់ជូនអ្នកនូវចំនួនប្រាក់ឧបត្ថម្ភដើម្បីជួយបង់ថ្លៃឧបករណ៍ជំនួយភ្នែក ដូចជា វ៉ែនតា (ដង និងកញ្ចក់) ឬឡេនស៍ភ្នែក។



## សុខភាពត្រចៀក

Clever Care ចង់ឱ្យអ្នកឮសំឡេងដ៏អស្ចារ្យទាំងអស់នៃពិភពលោក។ នោះហើយគឺជាមូលហេតុដែលយើងខ្ញុំផ្តល់ជូនអ្នកនូវចំនួនប្រាក់ឧបត្ថម្ភដើម្បីជួយបង់ថ្លៃដល់ជំនួយការស្តាប់នានា។

# ប្រាក់ឧបត្ថម្ភសុខភាពនិងសុខុមាលភាពដែលមានភាពបត់បែន

## Clever Care ដាក់ជម្រើសត្រលប់ទៅរកសុខុមាលភាពវិញ!

សមាជិករបស់យើងខ្ញុំទទួលបានប្រាក់ឧបត្ថម្ភដើម្បីជួយបង់ថ្លៃសេវាកម្មដែល Original Medicare ឬគម្រោង Medicare Advantage បច្ចុប្បន្នរបស់អ្នកមិនរ៉ាប់រង។



### ចំណាយប្រាក់ឧបត្ថម្ភរបស់អ្នកលើអត្ថប្រយោជន៍មួយ ឬអត្ថប្រយោជន៍ទាំងអស់ខាងក្រោម៖

**សកម្មភាពហាត់ប្រាណ៖** ដូចជា ការហាត់តៃជី សមាជិកភាពក្លឹបហាត់ប្រាណ កីឡាវាយកូនហ្គោល ឬសកម្មភាពហាត់ប្រាណជាក្រុម។ មានការរឹតត្បិតមួយចំនួន។

**របស់របរមិនតម្រូវឱ្យមានវេជ្ជបញ្ជា៖** ថ្នាំបំបាត់ការឈឺចាប់ដែលមិនមានវេជ្ជបញ្ជា ថ្នាំផ្តាសាយ ឬអាំឡេរបង្វ Band-Aids® និងថ្នាំជាច្រើនទៀត។

**អាហារបំប៉នធ្វើពីរុក្ខជាតិ៖** តែរុក្ខជាតិ ក្រែមលាបបំបាត់ការឈឺចាប់ ឬសារធាតុចម្រាញ់ និងសារធាតុបំប៉នផ្សេងទៀតក្នុងបំណងធ្វើឱ្យសុខភាព និងសុខុមាលភាពកាន់តែប្រសើរឡើង។

**យើងខ្ញុំលើកទឹកចិត្តអ្នកដែលចាប់អារម្មណ៍ក្នុងការសាកល្បងអាហារបំប៉នរុក្ខជាតិ ឬការព្យាបាលសុខុមាលភាពណាមួយ ឱ្យពិភាក្សាជាមួយគ្រូពេទ្យរបស់ពួកគេមុនពេលចាប់ផ្តើមរបប ឬការព្យាបាលណាមួយ។**

# ការទទួលបាន និងការបង់ថ្លៃសេវាកម្ម៖




បង្ហាញ **ប័ណ្ណសម្គាល់ Clever Care** របស់អ្នកនៅពេលណាដែលទទួលបានការថែទាំ សុខភាពភ្នែក សុខភាពមាត់ធ្មេញ សេវាកម្មបន្ថែមផ្សេងទៀត ឬការទិញឱសថមានវេជ្ជបញ្ជា។



# ប្រភេទនៃការបង់ប្រាក់

ខាងក្រោមនេះគឺជាការពិពណ៌នាសង្ខេបនៃការបង់ប្រាក់បីប្រភេទដែលអ្នកអាចតម្រូវឱ្យបង់សម្រាប់ថ្លៃសេវាកម្មដែលរ៉ាប់រងដោយគម្រោងរបស់យើងខ្ញុំ។



| | |
|---|---|
| **ការបង់ប្រាក់រួម** | ចំនួនទឹកប្រាក់កំណត់ ដែលអ្នកអាចតម្រូវឱ្យបង់ជាចំណែកនៃថ្លៃចំណាយសម្រាប់សេវាកម្មវេជ្ជសាស្ត្រ ការផ្គត់ផ្គង់ ឬឱសថមានវេជ្ជបញ្ជា។ |
| **ការធានារ៉ាប់រងរួម** | ចំនួនទឹកប្រាក់ដែលអ្នកអាចតម្រូវឱ្យបង់ជាចំណែកនៃថ្លៃចំណាយសម្រាប់សេវាកម្ម ឬឱសថមានវេជ្ជបញ្ជា។ ការធានារ៉ាប់រងរួម ជាធម្មតា គឺជាភាគរយនៃថ្លៃចំណាយសរុប (ឧទាហរណ៍ 20%) ។ |
| **ប្រាក់ឧបត្ថម្ភ** | ចំនួនកំណត់ ដែលត្រូវបង់ប្រចាំត្រីមាស ឬពាក់កណ្ដាលឆ្នាំដោយគម្រោងក្នុងគោលបំណងជាក់លាក់ដូចជា ការបង់ថ្លៃសេវាថែទាំសុខភាព។ |
| **ប្រាក់ឧបត្ថម្ភសុខភាព និងសុខុមាលភាព ដែលមានភាព បត់បែន**   | ប្រើ Flex Card ដើម្បីបង់ប្រាក់សម្រាប់ផលិតផល OTC អាហារបំប៉នធ្វើពីរុក្ខជាតិ និងសកម្មភាពហាត់ប្រាណដែលគ្រប់លក្ខន្តិកៈដោយប្រើថវិកាដែលមានរបស់អ្នក។ បណ្ណនេះស្រដៀងទៅនឹងបណ្ណឥណទាន ឬបណ្ណឥណពន្ធ – **សូមរក្សាវាឱ្យមានសុវត្ថិភាព។** |

# តើ Original Medicare ប្រៀបធៀបទៅនឹង Clever Care Medicare Advantage បានយ៉ាងដូចម្ដេច

Clever Care ផ្ដល់ជូនសមាជិករបស់យើងខ្ញុំនូវលទ្ធភាពទទួលបានសេវាកម្ម ដែល Original Medicare ឬគម្រោង Medicare Advantage បច្ចុប្បន្ន របស់អ្នកមិនរ៉ាប់រង។



**សូមមើលឯកសារ *ភស្តុតាងនៃការធានារ៉ាប់រង* នៃគម្រោង ជាក់លាក់សម្រាប់ព័ត៌មានលម្អិតពេញលេញនៃអត្ថ ប្រយោជន៍បន្ថែមទាំងអស់។**

# សុខុមាលភាពបែបលោកខាងកើត

| Original Medicare រ៉ាប់រងលើ៖ | Medicare Advantage (HMO) របស់ Clever Care រ៉ាប់រងលើ៖ | អ្វីដែលអ្នកចំណាយ៖ |
|---|---|---|
| • ការព្យាបាលដោយប្រើម្ជុលវិទ្យាសាស្ត្រដែលរ៉ាប់រងដោយ Medicare (រហូតដល់ការជួបព្យាបាលចំនួន 12 ដង) | អត្ថប្រយោជន៍ខុសគ្នាតាមគម្រោង។ សមាជិកទទួលបាន៖<br>• ការជួបព្យាបាលដោយប្រើម្ជុលវិទ្យាសាស្ត្រច្រើនជាង 12 ដង<br>• អតិបរមានៃសេវាកម្មសុខុមាលភាពបែបលោកខាងកើតចំនួន 12 ឬ 24 សេវាក្នុងមួយឆ្នាំតាមប្រតិទិន (រយៈពេល 30 នាទី)<br><br>សេវាកម្មរួមមាន៖<br>• Gua Sha<br>• Tui Na<br>• ការសិក្សាពីរ៉េផ្លិច<br>• ការព្យាបាលដោយជប់ខ្យល់<br>• ការព្យាបាលដោយ MedX | **ការបង់ប្រាក់រួម $0** ក្នុងការជួបព្យាបាលម្តង រហូតដល់ចំនួនអតិបរមានៃការជួបព្យាបាលដែលអនុញ្ញាតដោយគម្រោង<br><br>**ការបង់ប្រាក់រួម $0** ក្នុងការជួបព្យាបាលម្តង រហូតដល់ចំនួនអតិបរមានៃការជួបព្យាបាល និងរយៈពេលដែលបានអនុញ្ញាតដោយគម្រោង |
| **ចំណុចសំខាន់ដែលត្រូវដឹង៖** | សេវាកម្មសុខភាពបែបលោកខាងកើតទាំងអស់ត្រូវតែអនុវត្តដោយអ្នកផ្តល់សេវាក្នុងបណ្តាញរបស់ Clever Care ។ | |

សូមចូលទៅកាន់គេហទំព័រ **clevercarehealthplan.com** សម្រាប់បញ្ជីពេញលេញនៃសេវាកម្ម និង *មគ្គុទ្ទេសក៍ឆ្លាតវៃចំពោះអត្ថប្រយោជន៍ឱសថបែបលោកខាងកើត* របស់យើង

# មគ្គទេសក៍ឆ្លាតវៃចំពោះអត្ថប្រយោជន៍ឱសថបែបលោកខាងកើត

| Original Medicare រ៉ាប់រងលើ៖ | Clever Care Medicare Advantage (HMO) | អ្វីដែលអ្នកចំណាយ៖ |
|---|---|---|
| • **សកម្មភាពហាត់ប្រាណ៖** មិនមានការរ៉ាប់រង<br>• **មិនតម្រូវឱ្យមានវេជ្ជបញ្ជា (OTC) ៖** មិនមានការរ៉ាប់រង<br>• **អាហារបំប៉នផ្ទៃពីរុក្ខជាតិ៖** មិនមានការរ៉ាប់រង | ផ្តល់ជូនប្រាក់ឧបត្ថម្ភដែលមានភាពបត់បែនរៀងរាល់បីខែម្តង ដែលអាចត្រូវបានប្រើដើម្បីបង់ប្រាក់សម្រាប់៖<br>• សកម្មភាពហាត់ប្រាណដែលសមស្របតាមរបៀបរស់នៅរបស់អ្នក (មានការរឹតត្បិតមួយចំនួន)<br>• ឱសថ និងការផ្គត់ផ្គង់មិនតម្រូវឱ្យមានវេជ្ជបញ្ជាដែលមានគ្រប់លក្ខន្តិកៈ<br>• អាហារបំប៉នរុក្ខជាតិដែលមានគ្រប់លក្ខន្តិកៈ | **ការបង់ប្រាក់រួម $0** រហូតដល់ចំនួនប្រាក់ឧបត្ថម្ភ |
| **ព័ត៌មានលម្អិតអំពីប្រាក់ឧបត្ថម្ភ៖** | ចំនួនប្រាក់ឧបត្ថម្ភប្រែប្រួលតាមគម្រោង។ សមាជិករបស់ Balance ទទួលបានរហូតដល់ $300 រៀងរាល់ 3 ខែដើម្បីបង់ថ្លៃចំណាយលើអត្ថប្រយោជន៍សុខុមាលភាពដែលមានការរ៉ាប់រងមួយ ឬច្រើន។ | |

ជ្រើសរើសចំណាយប្រាក់ឧបត្ថម្ភរបស់អ្នកលើអត្ថប្រយោជន៍មួយ ឬទាំងអស់ក្នុងចំណោមអត្ថប្រយោជន៍ដែលមានការរ៉ាប់រង។ ***នោះគឺ Clever!***





# សុខភាពមាត់ធ្មេញ

| Original Medicare រ៉ាប់រងលើ៖ | Medicare Advantage (HMO) របស់ Clever Care រ៉ាប់រងលើ៖ | អ្វីដែលអ្នកចំណាយ៖ |
|---|---|---|
| • តែសេវាកម្មសុខភាពមាត់ធ្មេញប៉ុណ្ណោះពេលនៅក្នុងមន្ទីរពេទ្យ | ការថែទាំសុខភាពមាត់ធ្មេញជាប្រចាំរួមមាន៖<br>• ការសម្អាតធ្មេញ<br>• ការពិនិត្យមាត់<br>• ការព្យាបាលដោយសារធាតុភ្លុយអ័រ<br>• ការថតកម្មរស្មីអ៊ិច<br>ការព្យាបាលសុខភាពមាត់ធ្មេញគ្រប់ប្រភេទរួមមាន៖<br>• ការសម្អាតធ្មេញជ្រៅ<br>• ការប៉ះ និងការជួសជុលធ្មេញ<br>• ព្យាបាលការពុកនៅប្រហោងឬសធ្មេញ (ទន្តពេទ្យឯកទេសបណ្តូលធ្មេញ)<br>• ការស្រោបធ្មេញ (ការស្រោបពីលើ)<br>• ស្ពានធ្មេញ និងការដាំបង្គោល<br>• ការដាក់ធ្មេញ ការដកធ្មេញ និងសេវាកម្មផ្សេងទៀត | **ការបង់ប្រាក់រួម $0** សម្រាប់សេវាសុខភាពមាត់ធ្មេញ ( មិនរួមបញ្ចូលការដាំបង្គោលធ្មេញ) រហូតដល់ចំនួនប្រាក់ឧបត្ថម |
| **ព័ត៌មានលម្អិតអំពីប្រាក់ឧបត្ថម្ភ៖** | ចំនួនប្រាក់ឧបត្ថម្ភប្រែប្រួលតាមគម្រោង។ សមាជិក Longevity និង Balance អាចទទួលបានរហូតដល់ $2,500 ក្នុងមួយឆ្នាំដើម្បីប្រើប្រាស់សម្រាប់សេវាកម្មសុខភាពមាត់ធ្មេញដែលមានគ្រប់លក្ខន្តិកៈ។ | |



## សុខភាពភ្នែក

| Original Medicare រ៉ាប់រងលើ៖ | Medicare Advantage (HMO) របស់ Clever Care រ៉ាប់រងលើ៖ | អ្វីដែលអ្នកចំណាយ៖ |
|---|---|---|
| • ការពិនិត្យសុខភាពភ្នែកដើម្បីធ្វើរោគវិនិច្ឆ័យ/ព្យាបាលជំងឺ និងស្ថានភាពភ្នែក<br>• វ៉ែនតាក្រោយពេលវះកាត់ភ្នែកឡើងបាយ | • ការពិនិត្យភ្នែកជាប្រចាំ រួមទាំងចំណាំងផ្លាត<br>• វ៉ែនតា ឡេនស៍ភ្នែក ដង វ៉ែនតា និងច្រើនទៀត | **ការបង់ប្រាក់រួម $0** សម្រាប់ការពិនិត្យភ្នែកម្តង<br>**ការបង់ប្រាក់រួម $0** សម្រាប់ឧបករណ៍ជំនួយភ្នែករហូតដល់ចំនួនប្រាក់ឧបត្ថម |
| **ព័ត៌មានលម្អិតអំពីប្រាក់ឧបត្ថម្ភ៖** | ចំនួនប្រាក់ឧបត្ថម្ភប្រែប្រួលតាមគម្រោង។ សមាជិករបស់ Longevity និង Fortune ទទួលបាន $480 រៀងរាល់ពីរឆ្នាំម្តងដើម្បីប្រើសម្រាប់ឧបករណ៍ជំនួយភ្នែក និងឡេនស៍ភ្នែក។ | |



# សុខភាពត្រចៀក

| Original Medicare រ៉ាប់រងលើ៖ | Medicare Advantage (HMO) របស់ Clever Care រ៉ាប់រងលើ៖ | អ្វីដែលអ្នកចំណាយ៖ |
| --- | --- | --- |
| • ការពិនិត្យសុខភាពត្រចៀកក្នុងការធ្វើរោគវិនិច្ឆយ | • ការពិនិត្យសុខភាពត្រចៀកជាប្រចាំ<br>• ជំនួយការស្តាប់រួមទាំងកាសពាក់ត្រចៀក និងការវាយតម្លៃ | **ការបង់ប្រាក់រួម $0** សម្រាប់ការពិនិត្យសុខភាពត្រចៀកជាប្រចាំម្តង។<br>**ការបង់ប្រាក់រួម $0** សម្រាប់ជំនួយការស្តាប់រហូតដល់ចំនួនប្រាក់ឧបត្ថម។ |
| **ព័ត៌មានលម្អិតអំពប្រាក់ឧបត្ថម្ភ៖** | ចំនួនប្រាក់ឧបត្ថម្ភប្រែប្រួលតាមគម្រោង។ សមាជិករបស់ Balance ទទួលបានរហូតដល់ $1,500 ក្នុងត្រចៀកម្ខាងជារៀងរាល់ឆ្នាំសម្រាប់ជំនួយការស្តាប់។ | |

ប្រាក់ឧបត្ថម្ភនេះនឹងគ្របដណ្តប់លើថ្លៃចំណាយនៃជំនួយការស្តាប់មូលដ្ឋាន។

Clever Care HEALTH PLAN

ដៃគូរបស់លោកអ្នកសម្រាប់ការថែទាំសុខភាពដ៏ទូលំទូលាយ

## សូមទាក់ទងមកយើងខ្ញុំ

**(833) 365-1888 (TTY: 711) | info@ccmapd.com**

**ឬទូរសព្ទទៅអ្នកប្រឹក្សាយោបល់ផ្នែក Medicare ដែលមានអាជ្ញាប័ណ្ណផ្ទាល់ខ្លួនរបស់អ្នក**

**ថ្ងៃទី 1 ខែតុលា ដល់ថ្ងៃទី 31 ខែមីនា៖**
ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍
**ថ្ងៃទី 1 ខែមេសា ដល់ថ្ងៃទី 30 ខែកញ្ញា៖**
ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ

គម្រោង Clever Care Heath Plan Inc. គឺជាគម្រោង HMO ដែលមានកិច្ចសន្យាជាមួយនឹង Medicare ។ ការចុះឈ្មោះអាស្រ័យលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ អ្នកផ្តល់សេវាកម្មក្នុងបណ្តាញរបស់យើងខ្ញុំអាចផ្លាស់ប្តូរគ្រប់ពេលវេលា។ អ្នកនឹងទទួលបានការជូនដំណឹងនៅពេលចាំបាច់។

និមិត្តសញ្ញា ឬពាណិជ្ជសញ្ញាទាំងអស់ដែលបានបង្ហាញនៅក្នុងការណែនាំនេះ គឺជាកម្មសិទ្ធិរបស់ម្ចាស់រៀងៗខ្លួន។

©2021 Clever Care Heath Plan, Inc. រក្សាសិទ្ធិគ្រប់យ៉ាង។

M10095-F-KM (10/21)